**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០១៩៨_រថ.អវថ.ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

ថ្ងៃ អង្គារ ១៣ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២០

# ប្រកាស

## ស្តីពីការដាក់ឲ្យអនុវត្តផែនការអនុគ្រោះ និងលើកទឹកចិត្តចំពោះការប្រើប្រាស់ អគ្គិសនី របស់វិស័យឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ពីខែ មិថុនា ដល់ខែ តុលា ឆ្នាំ ២០២០

## ក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស០៩១/រកត/៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- យោងប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ ០០៤០.រថ.អវថ.ប្រក. ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ ស្តីពីការដាក់ឲ្យអនុវត្តផែនការបន្ថយថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ និងផែនការកែទម្រង់ការបង់ថ្លៃអគ្គិសនីរបស់អ្នកប្រើប្រាស់ សម្រាប់ឆ្នាំ ២០២០ និងឆ្នាំ ២០២១
- យោងលទ្ធផលនៃកិច្ចប្រជុំសម្រេចរវាងក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២០ ស្តីពីផែនការអនុគ្រោះ និងលើកទឹកចិត្តចំពោះការប្រើប្រាស់អគ្គិសនីរបស់វិស័យឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ក្នុងរយៈពេលអនុវត្តការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ការចំលងមេរោគកូវីដ ១៩
- ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០២០ លើលិខិតលេខ ០៩១៦ រថ.អថ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២០ របស់ក្រសួងរ៉ែ និងថាមពល ។

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

## សម្រេច

**ប្រការ ១._**

ដាក់ឱ្យអនុវត្ត «ផែនការអនុគ្រោះ និងលើកទឹកចិត្តចំពោះការប្រើប្រាស់អគ្គិសនីរបស់វិស័យឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ពីខែ មិថុនា ដល់ខែ តុលា ឆ្នាំ ២០២០» ដែលមានគោលដៅកែសម្រួលការបង់ថ្លៃប្រើប្រាស់អគ្គិសនី ដែលទីតាំងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម បានប្រើពីខែ មិថុនា ដល់ខែ តុលា ឆ្នាំ ២០២០» ដើម្បីជួយសម្រួលទាំងការលំបាកក្នុងការបង់ថ្លៃអគ្គិសនីរបស់ទីតាំងដែលបានព្យួរ ឬបន្ថយសកម្មភាពផលិតកម្ម ឬអាជីវកម្ម និងទាំងជួយលើកទឹកចិត្តចំពោះការប្រើប្រាស់អគ្គិសនីរបស់ទីតាំងដែលមានបរិយាកាសអំណោយផល អាចបង្កើនសកម្មភាពផលិតកម្ម ឬ អាជីវកម្ម ក្នុងរយៈពេលអនុវត្តការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ការចំលងមេរោគកូវីដ ១៩ ។ «ផែនការអនុគ្រោះ និងលើកទឹកចិត្តចំពោះការប្រើប្រាស់អគ្គិសនីរបស់វិស័យឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ពីខែ មិថុនា ដល់ខែ តុលា ឆ្នាំ ២០២០» មានខ្លឹមសារ ដូចខាងក្រោម៖

- ទី១. ផ្តល់ការអនុគ្រោះលើកលែងការបង់ថ្លៃអគ្គិសនីតាមលក្ខខណ្ឌអប្បបរមា និងលើកលែងការបង់ថ្លៃតាមលក្ខខណ្ឌអានុភាព រួចអនុញ្ញាតឱ្យបង់ថ្លៃអគ្គិសនីត្រឹមតែចំនួនគីឡូវ៉ាត់ម៉ោង ដែលបានប្រើប្រាស់ជាក់ស្តែង តាមអត្រាថ្លៃមធ្យម ចំពោះទីតាំងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្មណាដែលរងគ្រោះដោយការព្យួរ ឬ បន្ថយសកម្មភាពផលិតកម្ម ឬ អាជីវកម្ម ទោះជាទីតាំងនោះប្រើអគ្គិសនីដែលផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា ឬ ក៏ផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់ឯកជន ដែលទិញប្រភពអគ្គិសនី ពី អគ្គិសនីកម្ពុជា ក៏ដោយ ។
- ទី២. រក្សាស្ថានភាពផ្គត់ផ្គង់ និងការបង់ថ្លៃអគ្គិសនីដូចមុន ដោយមិនមានការកែប្រែចំពោះទីតាំងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្មណា ដែលមិនមានការប៉ះពាល់ធំដុំ អាចបន្តដំណើរការផលិតកម្ម ឬអាជីវកម្មរបស់ខ្លួនជាធម្មតាប្រហាក់ប្រហែលពេលមុន ។
- ទី៣. ផ្តល់ការលើកទឹកចិត្តដោយបន្ថយថ្លៃអគ្គិសនីចំនួន ២៥% លើការបង់ថ្លៃអគ្គិសនីដែលបានប្រើលើសពីចំនួនប្រើប្រចាំខែមធ្យមក្នុងរយៈពេល ៣ ខែ ដើមឆ្នាំ (ពីខែ មករា ដល់ខែ មីនា) ចំពោះទីតាំងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ណា ដែលបរិយាកាសអំណោយផលអាចបង្កើនសកម្មភាពផលិតកម្ម ឬ អាជីវកម្មរបស់ខ្លួន ជួយទប់ការថយចុះនៃសេដ្ឋកិច្ច ក្នុងរយៈពេលអនុវត្តការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ការចំលងមេរោគកូវីដ ១៩ ។

**ប្រការ ២._**

«ផែនការអនុគ្រោះ និងលើកទឹកចិត្តចំពោះការប្រើប្រាស់អគ្គិសនីរបស់វិស័យឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ពីខែ មិថុនា ដល់ខែ តុលា ឆ្នាំ ២០២០» ដែលដាក់ឱ្យអនុវត្តនៅក្នុងប្រកាសនេះ មានវិសាលភាពអនុវត្តលើការផ្គត់ផ្គង់អគ្គិសនីទាំងឡាយ ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ ទាំងការផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាផ្ទាល់ និងទាំងការផ្គត់ផ្គង់ដោយអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរង ឬចែកចាយអគ្គិសនី

ឯកជន។ ផែនការនេះ គ្រាន់តែជាផែនការដែលអនុញ្ញាតឲ្យមានការអនុវត្តដោយឡែក ចំពោះអ្នកប្រើប្រាស់អគ្គិសនីដែលបានកំណត់ក្នុងប្រការ ១ ខាងលើ នៅក្នុងរយៈពេលនៃការប្រើប្រាស់អគ្គិសនីពីខែ មិថុនា ដល់ខែ តុលា ឆ្នាំ ២០២០ ប៉ុណ្ណោះ មិនមែនជាការធ្វើវិសោធនកម្មខ្លឹមសារ "ផែនការបន្ថយថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ និងផែនការកែទម្រង់ការបង់ថ្លៃអគ្គិសនីរបស់អ្នកប្រើប្រាស់ សម្រាប់ឆ្នាំ ២០២០ និងឆ្នាំ ២០២១" ដែលដាក់ឲ្យអនុវត្តដោយប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ ០០៤០.រ៉ថ.អវថ.ប្រក. ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ ឡើយ ។

**ប្រការ ៣._**

ការផ្តល់ការអនុគ្រោះលើកលែងការបង់ថ្លៃអគ្គិសនីតាមលក្ខខណ្ឌអប្បបរមា និងលើកលែងការបង់ថ្លៃតាមលក្ខខណ្ឌអានុភាព រួចអនុញ្ញាតឲ្យបង់ថ្លៃអគ្គិសនីត្រឹមតែចំនួនគីឡូវ៉ាត់ម៉ោង ដែលបានប្រើជាក់ស្តែងតាមអត្រាថ្លៃមធ្យម ចំពោះទីតាំងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ណា ដែលរងគ្រោះដោយការព្យួរ ឬ បន្ថយសកម្មភាពផលិតកម្ម ឬ អាជីវកម្ម គឺជាបន្ទុកផ្ទាល់របស់អ្នកផ្គត់ផ្គង់អគ្គិសនីនៃទីតាំងនីមួយៗ ។ ការលើកទឹកចិត្តដោយបន្ថយថ្លៃអគ្គិសនីចំនួន ២៥% លើការបង់ថ្លៃអគ្គិសនីដែលបានប្រើលើសពីចំនួនប្រើប្រចាំខែមធ្យមក្នុងរយៈពេល ៣ ខែ ដើមឆ្នាំ (ពីខែ មករា ដល់ខែ មីនា) ចំពោះទីតាំងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ដែលបរិយាកាសអំណោយផល អាចបង្កើនសកម្មភាពផលិតកម្ម ឬ អាជីវកម្មរបស់ខ្លួន ជួយទប់ការថយចុះនៃសេដ្ឋកិច្ច ក្នុងរយៈពេលអនុវត្តការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ការចំលងមេរោគកូវីដ ១៩ គឺជាបន្ទុករបស់អគ្គិសនីកម្ពុជា ទាំងក្នុងការផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាផ្ទាល់ និងទាំងក្នុងការផ្គត់ផ្គង់ដោយអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរង ឬចែកចាយអគ្គិសនីឯកជន ដែលយកប្រភពអគ្គិសនី ពី អគ្គិសនីកម្ពុជា ។

**ប្រការ ៤._**

ពេលវេលា វិធានការ យន្តការប៉ះប៉ូវរបស់អគ្គិសនីកម្ពុជា ដើម្បីឲ្យអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរង ឬចែកចាយអគ្គិសនីឯកជន អនុវត្តការលើកទឹកចិត្តឲ្យទីតាំងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម និងលក្ខខណ្ឌលម្អិតនៃការអនុវត្តផែនការខាងលើ អាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការសម្រេច និងដាក់ឲ្យអនុវត្ត ទៅតាមការកំណត់របស់ច្បាប់ ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៥._**

អង្គភាព និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលរួមមាន អគ្គនាយកដ្ឋានថាមពល មន្ទីររ៉ែ និងថាមពលរាជធានី/ខេត្ត អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាបណ្ណធ្វើសេវាកម្មបញ្ជូនរង និងចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរួមគ្នាអនុវត្ត "ផែនការអនុគ្រោះ និងលើកទឹកចិត្តចំពោះការប្រើប្រាស់អគ្គិសនីរបស់វិស័យឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ពីខែ មិថុនា ដល់ខែ តុលា ឆ្នាំ ២០២០" ដែលបានកំណត់នៅក្នុងប្រកាសនេះ ឲ្យបានសុក្រឹត និងមានប្រសិទ្ធភាព ដើម្បីឈានទៅសម្រេច

គោលដៅជួយសម្រួលដល់ការលំបាក និងជួយលើកទឹកចិត្ត ចំពោះការប្រើប្រាស់អគ្គិសនីរបស់ទីតាំងឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ក្នុងរយៈពេលអនុវត្តការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់ការចំលងមេរោគកូវីដ ១៩ ។

**ប្រការ ៦._**

ប្រកាស និងសេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងការកំណត់ក្នុងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ក្នុងរយៈពេលនៃការអនុវត្តប្រកាសនេះ ។

**ប្រការ ៧._**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់ផែនការក្នុងប្រការ ១ ត្រូវបានបញ្ចប់ ។

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

ស៊ុយ_សែម

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់រដ្ឋបាលរាជធានី ខេត្ត
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ